# សេចក្តីជូនដំណឹង
# ស្តីពី
# ការធ្វើបរិវិសកម្មសញ្ញាបណ្ណបន្ទាប់បន្សំដំណាក់កាលទីមួយ
# របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) ជាធនាគារពាណិជ្ជទីមួយដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅផ្សារមូលបត្រកម្ពុជា (ផមក) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជន មេត្តាជ្រាបថា ធនាគារ អេស៊ីលីដា បានទទួលការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា និងនិយ័តករមូលបត្រកម្ពុជា ក្នុងការបោះផ្សាយលក់សញ្ញាបណ្ណបន្ទាប់បន្សំក្នុងទំហំទឹកប្រាក់រហូតដល់ ៤០០ពាន់លានរៀល ប្រមាណជា ១០០លានដុល្លារអាមេរិក ស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។ ការបោះផ្សាយលក់សញ្ញាបណ្ណបន្ទាប់បន្សំនេះ ធនាគារ អេស៊ីលីដា មានគម្រោងរៀបចំធ្វើបរិវិសកម្មជាបួនដំណាក់កាល។ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ធនាគារ អេស៊ីលីដា បានធ្វើបរិវិសកម្មដំណាក់កាលទីមួយ ប្រកបដោយភាពជោគជ័យ ដែលមានវិនិយោគិនគុណវុឌ្ឍិបញ្ជាទិញសញ្ញាបណ្ណរហូតដល់ ៣៤៣.៣៥០.០០០.០០០រៀល សមមូលជាប្រាក់ដុល្លារស្មើនឹង ៨៥.៨៣៧.៥០០ដុល្លារអាមេរិក ដែលជាលទ្ធផលទទួលបានទំនុកចិត្ត និងការជឿជាក់ពីវិនិយោគិនលើធនាគារ អេស៊ីលីដា លើសពីការរំពឹងទុក។ ទន្ទឹមនឹងនេះ ធនាគារ អេស៊ីលីដា នឹងជូនដំណឹងដល់វិនិយោគិន និងសាធារណជន អំពីការធ្វើបរិវិសកម្មទៅលើចំនួនសញ្ញាបណ្ណបន្ទាប់បន្សំដំណាក់កាលទីពីរនាពេលបន្ទាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម វិនិយោគិន និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP